**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ: ០៥ ដនស/អសណ

ភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់

**យោង** : -អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់

ដើម្បីរៀបចំឱ្យមានការទទួលខុសត្រូវច្បាស់លាស់តាមមុខជំនាញបច្ចេកទេសលើរាល់គំរោងប្លង់ សុំការអនុញ្ញាតសាងសង់ សំដៅធានាគុណភាព សុវត្ថិភាពសំណង់នោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជូនដំណឹងដល់សាធារណៈជន និងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា :

១-រូបវន្តបុគ្គលសិក្សាគំរោងប្លង់ដែលជាស្ថាបត្យករ វិស្វករដែលចុះហត្ថលេខាទទួលខុសត្រូវលើរាល់ឯកសារគំរោងប្លង់សុំការអនុញ្ញាតសាងសង់ ត្រូវចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

២-ហត្ថលេខារបស់រូបវន្តបុគ្គលណា ដែលមិនបានចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់ទុកថា មិនមានលក្ខណៈគតិយុត្តគ្រប់គ្រាន់ ដើម្បីបញ្ជាក់ការទទួលខុសត្រូវរបស់រូបវន្តបុគ្គលនោះលើគំរោងប្លង់ឡើយ ។

៣-ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សូមរូបវន្តបុគ្គលសិក្សាគំរោងប្លង់ទាំងអស់ អញ្ជើញមកចុះបញ្ជីនៅនាយកដ្ឋានសិក្សាគំរោងប្លង់ នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀងរាល់ម៉ោងធ្វើការ ដែលមានអាស័យដ្ឋានលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

ចំលងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងដ.ន.ស
-គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត ក្រុង ដើម្បីអនុវត្ត
-ឯកសារ កាលប្បវត្តិ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ**

**Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh**